ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ សរ.

ក្រសួងធនធានទឹក និង ឧតុនិយម
ចូល លេខ: 175
ថ្ងៃទី 11.01.99 ម៉ោង........
បញ្ជូន......................

***

# សារាចរ

## ស្តីពី

## ការអនុវត្តន៍គោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ

វិស័យកសិកម្មនៅកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិព្រោះថាប្រជាជនប្រមាណ 85% ជាកសិករ ។ ដូចនេះដើម្បីធានាបានលើផ្នែកសន្តិសុខស្បៀងឈានដល់ការនាំ កសិផលចេញ ការងារដោះស្រាយទឹកត្រូវបានចាត់ទុកជាកត្តាគន្លឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលប្រកាន់យក និង វារឹតតែមាន តួនាទីពិសេសទៅទៀតសំរាប់នាពេលបច្ចុប្បន្ន និង អនាគត ។ ឈរលើទស្សនៈ ខាងលើនេះ ការងារស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ បាននិងកំពុងក្លាយជាចលនាមួយយ៉ាងផុលផុសពីសំណាក់រាជរដ្ឋាភិបាល អង្គការសង្គម អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និង សប្បុរសជន ។ល។ ទន្ទឹមនឹងនេះក្នុងគោលបំណង :

- ជំរុញដល់ការដាំដុះធានាបាននូវសុវត្ថិភាពស្បៀង និង ការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិ ។
- ថែទាំប្រព័ន្ធស្រោចស្រពក្នុងលក្ខណៈប្រើប្រាស់យូរអង្វែង ។
- ពង្រីកបាននូវសមត្ថភាពប្រើប្រាស់ និង សក្តានុពលនៃការស្រោចស្រព ។
- កាត់បន្ថយនូវការចំណាយជាប្រចាំដ៏ធំធេងរបស់រាជរដ្ឋាភិបាល លើកិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រ ។
- ទប់ស្កាត់នូវភាពអនាធិបតេយ្យនៃការកសាងប្រព័ន្ធធារាសាស្ត្រ និង ការបំផ្លិចបំផ្លាញ ។
- ទាក់ទាញនូវប្រភពធនធានថវិកាពីអន្តរជាតិ សប្បុរសជនដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍វិស័យធារាសាស្ត្រ ។
- ជំរុញអោយកសិករមានភាពម្ចាស់ការលើការប្រើប្រាស់ និង ថែទាំប្រព័ន្ធស្រោចស្រព ដែលឈានទៅដល់ការផ្ទេរការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រអោយដល់សហគមន៍កសិករប្រើប្រាស់ទឹក ។

ដើម្បីអនុវត្តន៍គោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនក្រសួងធនធានទឹក និង ឧតុនិយម :

- ត្រូវធ្វើការពិនិត្យពិចារណា និង ធ្វើការវាយតំលៃនូវរាល់ប្រព័ន្ធធារាសាស្ត្រទូទាំងប្រទេសដែលបំរើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។
- ត្រូវរៀបចំលក្ខន្តិកៈសហគមន៍កសិករប្រើប្រាស់ទឹកជាគំរូទូទាំងប្រទេស និង ទទួលបន្ទុកណែនាំការងាររៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ។
- ត្រូវធ្វើការសិក្សាគ្រោងប្លង់ និង សាងសង់ទាំងស្រុងនូវសំណង់ប្រព័ន្ធស្រោចស្រពដើម្បីធ្វើយ៉ាងណាធានាដល់ការផ្គត់ទឹកដល់ស្រែ ចំការដំណាំរបស់កសិករ ។
- ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធក្នុងការរៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសហការរៀបចំថវិកាដល់កិច្ចដំណើរការសហគមន៍កសិករប្រើប្រាស់ទឹក រហូតដល់ សហគមន៍អាចដំណើរការដោយខ្លួនឯងបាន ក្នុងនោះត្រូវអនុវត្តទៅតាមរូបមន្តដូចខាងក្រោម ។

- ការកំណត់ថ្លៃទឹកសំរេចដោយសហគមន៍កសិករប្រើប្រាស់ទឹកក្នុងមួយហិកតា :

$$Y = \frac{X_1 + X_2 + X_3 + X_4 + X_5}{\text{ផ្ទៃដីស្រោចស្រព}} + 20\%$$ នៃអត្រាកំណើនទិន្នផលក្នុងមួយហិកតា

ក្នុងនេះ X តាងដោយការចំណាយដល់កិច្ចដំណើរការថែទាំ :

$X_1$ = ការចំណាយលើ ការងារជួសជុល និង ថែទាំប្រព័ន្ធស្រោចស្រព

$X_2$ = ការចំណាយលើ ប្រេងឥន្ធនៈ (ក្នុងករណីប្រើប្រាស់ម៉ាស៊ីនបូមទឹក)

$X_3$ = ការចំណាយលើ ការឧបត្ថម្ភដល់គណៈកម្មាធិការសហគមន៍

$X_4$ = ការចំណាយលើ ផ្នែករដ្ឋបាល

$X_5$ = ការចំណាយលើ ការងារថែរក្សា

ហើយ Y តាងដោយការកំណត់ថ្លៃទឹកដូចតទៅ :

+ ក្នុងឆ្នាំទី 1 រដ្ឋទទួលបន្ទុក 80% សហគមន៍ត្រូវបង់ 20%
+ ក្នុងឆ្នាំទី 2 រដ្ឋទទួលបន្ទុក 60% សហគមន៍ត្រូវបង់ 40%
+ ក្នុងឆ្នាំទី 3 រដ្ឋទទួលបន្ទុក 40% សហគមន៍ត្រូវបង់ 60%
+ ក្នុងឆ្នាំទី 4 រដ្ឋទទួលបន្ទុក 20% សហគមន៍ត្រូវបង់ 80%
+ ក្នុងឆ្នាំទី 5 រដ្ឋទទួលបន្ទុក 0% សហគមន៍ត្រូវបង់ 100%

តំរោងចំណាយខាងលើនេះ គិតសំរាប់តែប្រភេទសំណង់ប្រព័ន្ធធារាសាស្ត្រណា ដែលស្ថាបនាឡើងដោយថវិការដ្ឋ ។

- ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកត្រូវកំណត់ដោយអក្សរកាត់ "ស.ក.ប.ទ" ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។ ស.ក.ប.ទ ត្រូវដឹកនាំដោយគណៈកម្មាធិការសហគមន៍ដែលត្រូវជ្រើសតាំងឡើងតាមរយៈនៃការបោះឆ្នោតរបស់សមាជិកសហគមន៍ ។ គណៈកម្មាធិការ ស.ក.ប.ទ ត្រូវមានភារកិច្ចដូចខាងក្រោម :
  - រៀបចំកម្មវិធីការងាររបស់សហគមន៍
  - អនុវត្តទៅតាមលក្ខន្តិកៈនៃសហគមន៍ដែលបានកំណត់ដោយក្រសួងធនធានទឹក និង ឧតុនិយម
  - រៀបចំកិច្ចដំណើរការ និង ការថែទាំប្រព័ន្ធធារាសាស្ត្រអោយស្ថិតក្នុងក្របខ័ណ្ឌប្រើប្រាស់ក៏រិត ខ្ពស់ និង សន្សំសំចៃ
  - ដោះស្រាយវិបត្តិរបស់សមាជិកសហគមន៍
  - ប្រមូលថ្លៃប្រើប្រាស់ទឹកស្រោចស្រពទៅតាមការកំណត់របស់សហគមន៍
  - ក៏រិតនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយសហគមន៍កសិករប្រើប្រាស់ទឹក ត្រូវបានកំណត់ភារកិច្ចមួយដោយឡែកទៅតាមភូមិសាស្ត្រ ប្រភេទគំរោងជាក់ស្តែងដែលកំណត់ដោយក្រសួងធនធានទឹក និងឧតុនិយម ។

- ស.ក.ប.ទ ត្រូវរៀបចំក្រុមកសិករប្រើប្រាស់ទឹកដែលតំណាងដោយអក្សរកាត់ "ក.ក.ប.ទ"
- ក.ក.ប.ទ មានភារៈកិច្ច :
  - អនុវត្តបណ្តាកម្មវិធីការងាររបស់សហគមន៍
  - សំរបសំរួលការងាររវាងសមាជិកក្រុម និង សហគមន៍
  - ប្រមូលថ្លៃប្រើប្រាស់ទឹកពីសមាជិកក្រុមរបស់ខ្លួនតាមការកំណត់របស់សហគមន៍

សមាជិកក្រុមកសិករប្រើប្រាស់ទឹកចាំបាច់ត្រូវដាក់ពាក្យសុំចូលជាសមាជិកក្រុមប្រើប្រាស់ទឹក ដោយផ្អែកលើលក្ខន្តិកៈសហគមន៍ (ភ្ជាប់ឧបសម្ព័ន្ធ) ។

រាជរដ្ឋាភិបាលលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ឬ បុគ្គលដែលមកបណ្តាក់ទុនវិនិយោគលើការងារធារាសាស្ត្រទំហំតូច និង ទំហំធំ ដោយបង្កើតជាសហគមន៍កសិករប្រើប្រាស់ទឹក ។ រីឯការ កំណត់ថ្លៃប្រើប្រាស់ទឹកអាស្រ័យដោយមានការឯកភាពស្រុះស្រួលគ្នារវាងអ្នកវិនិយោគ និង សហគមន៍កសិករ ប្រើប្រាស់ទឹក ដោយមានការយល់ព្រមពីក្រសួងធនធានទឹក និង ឧតុនិយម ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្តៅបំផុតចំពោះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិនានានឹងលើកកំពស់ឆន្ទៈអនុវត្តសារាចរនេះអោយបានជោគជ័យ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែមករា ឆ្នាំ១៩៩៩

ហ៊ុន សែន

ចំលងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ